ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូង**
**ខេត្តបន្ទាយមានជ័យ**

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តបន្ទាយមានជ័យ

សំណុំរឿងព្រហ្មទណ្ឌលេខ : ១១៧២
ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០
ជំនុំជម្រះថ្ងៃទី : ២៦-មករា-២០២១
សាលក្រមលេខ : **០៩"ឈ"/៨៤**
ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១

បានបើកសវនាការជាអសាធារណៈ នៅសាលាដំបូងខេត្តបន្ទាយមានជ័យ នាថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ប្រាំបួនព្រឹក។

បានប្រកាសសាលក្រមជាអសាធារណៈ នាថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង បីរសៀល។

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងអយ្យការ</u>**

- លោក [redacted] ជាព្រះរាជអាជ្ញារង

**<u>ក្រឡាបញ្ជីសវនាការ</u>**

- កញ្ញា [redacted] ជាក្រឡាបញ្ជី

**<u>មេធាវី</u>**

- លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ[redacted]ទី និងឈ្មោះ[redacted]សេងហុង
- កញ្ញា [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ[redacted]ទី និងឈ្មោះ[redacted]សេងហុង

## ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ១១៧២ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ ដែលមានជនជាប់ចោទដូចខាងក្រោម ៖

**១.ឈ្មោះ [redacted] ទី** ភេទប្រុស កើតថ្ងៃទី២៥.០១.២០០៣ អនីតិជន សញ្ជាតិខ្មែរ មុខរបរគ្មាន សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ [redacted] ខេត្តក្រចេះ អាសយដ្ឋានមុនពេលឃុំខ្លួនភូមិ [redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] ង៉ូវ (រស់) ម្តាយឈ្មោះ [redacted] ម៉ៃ (រស់) នៅលើវប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ **ធ្លាប់ចូលមណ្ឌលអប់រំកែប្រែព្រៃភ្នំបាក់ឆ្នាំ២០២០។** (ក្នុងឃុំ)

(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ : ៦៣៨ ព្រ.ទ III "គ"/២០ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០)

**២.ឈ្មោះ [redacted] សេងហុង** ភេទប្រុស កើតថ្ងៃទី២២.១០.២០០២ អនីតិជន សញ្ជាតិខ្មែរ មុខរបរជាងឡាន សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ [redacted] ខេត្តសៀមរាប អាសយដ្ឋានមុនពេលឃុំខ្លួនភូមិ [redacted] ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] ហួយ (រស់) ម្តាយឈ្មោះ [redacted] សុភាព (រស់) ប្រពន្ធឈ្មោះ [redacted] រក្សា មានកូនចំនួន ០២នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ **ធ្លាប់ចូលមណ្ឌលអប់រំកែប្រែសៀមរាបចំនួន០២ខែ។** (ក្នុងឃុំ)

(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ : ៦៣៩ ព្រ.ទ III "គ"/២០ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០)

ជាប់ចោទពីបទ **"លួច"** ប្រព្រឹត្តនៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

## អង្គហេតុកើតឡើងមានដូចតទៅ :

កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង៩:៣០នាទី ឈ្មោះ [redacted] សូវៀត ភេទប្រុស អាយុ ៣៥ឆ្នាំ បានជិះម៉ូតូមួយគ្រឿងម៉ាក ហុងដាឌ្រីម ស៊េរីឆ្នាំ២០១៩ ពណ៌ខ្មៅ ពាក់ស្លាកលេខ បន្ទាយមានជ័យ 1U-3137 ទៅធ្វើការងារនៅកន្លែងផ្ទះសំណាក់ លី ហ៊្សូវ ស្ថិតនៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ហើយបានទុកម៉ូតូនៅមុខផ្ទះសំណាក់។ លុះដល់ម៉ោងប្រហែល ០២រសៀល ឈ្មោះ [redacted] សូវៀត បានចេញពីធ្វើការវិញ ហើយដើរមករកម៉ូតូខាងលើស្រាប់តែបាត់ម៉ូតូនោះ។ បន្ទាប់មកឈ្មោះ [redacted] សូវៀត ក៏បានដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ច។ ក្រោយពីទទួលបានពាក្យបណ្តឹង សមត្ថកិច្ចនគរបាលក្រុងប៉ោយប៉ែត បានសហការជាមួយកម្លាំងនគរបាលស្រុកម៉ាឡៃ ធ្វើការស្រាវជ្រាវ និងឃាត់ខ្លួនជនសង្ស័យចំនួន ០២នាក់ រួមមានឈ្មោះ [redacted] សេងហុង ភេទប្រុស អាយុ ១៨ឆ្នាំ និងឈ្មោះ [redacted] ទី ភេទប្រុស អាយុ ១៧ឆ្នាំ និងបានដកហូតម៉ូតូខាងលើប្រគល់ឱ្យម្ចាស់ដើមវិញ។ ចំណែកជនសង្ស័យទាំង០២នាក់ ត្រូវបានសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនមកកាន់អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនីតិវិធី។

បានឃើញ : ដីកាសន្និដ្ឋានស្ថាពរលេខ : ១១៤២ អយខ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០។

បានឃើញ : ដីកាដំណោះស្រាយលេខ : ៥២៣១ ពស.ព្រស-"គ"/២០ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០។

បានឃើញ : ដីកាចាត់តាំងក្រុមប្រឹក្សាចៅក្រមជំនុំជម្រះលេខ : ២៣ ពស.ព្រជ-"ក"/២០ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១។



Scanned with CamScanner

បានឃើញ : ឯកសារនានាក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ : ១១៧២ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ ២០២១។

បានឃើញ : ការផ្តល់ និងការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការ ដែលធ្វើឡើងអនុលោមតាមបញ្ញត្តិមាត្រា ២៩២ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**នាពេលសវនាការ** :

- ក្រោយពីបាន ស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ឌី**
- ក្រោយពីបាន ស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សេងហុង**
- ក្រោយពីបាន ស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុខៀត**
- ក្រោយពីបាន ពិនិត្យឯកសារ និង វត្ថុតាងនានាដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងនេះ
- ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបាន ស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបាន ពិនិត្យ ពិភាក្សា និងពិចារណា ត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងខេត្ត បន្ទាយមានជ័យ**

**យល់ឃើញថា** :

១.តាមរយៈដីកាដំណោះស្រាយ លេខ : ៥២៣១ ពស.ព្រស-គ-/២០ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **ឌី** ភេទប្រុស កើតថ្ងៃទី២៥.០១.២០០៣ និងឈ្មោះ [redacted] **សេងហុង** ភេទប្រុស កើតថ្ងៃទី២២.១០.២០០២ មកធ្វើការជំនុំជម្រះពីបទ **"លួច"** ប្រព្រឹត្ត នៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ ២០២០ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

២.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ឌី** បានឆ្លើយនាពេលសវនាការថា : កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ខ្លួនបានណាត់ទៅឈ្មោះ [redacted] សេងហុង ភេទប្រុស ដើម្បីបបួលវាទៅលេងហ្គេមជាមួយគ្នា ប៉ុន្តែគេរវល់ទៅទិញប៉ុងឡានឱ្យឪពុករបស់គេ។ បន្ទាប់មកនៅវេលាម៉ោងប្រហែល ៦យប់ ទើបឈ្មោះ [redacted] សេងហុង មកដល់ប៉ោយប៉ែត ដោយពេលនោះភ្លៀងផង ខ្លួនបានដេកនៅប៉ោយប៉ែតមួយយប់សិន។ លុះព្រឹកឡើងនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២០ ខ្លួនមានបំណងទៅលេងខេត្តសៀមរាបជាមួយ និងឈ្មោះ [redacted] សេងហុង ដោយជិះម៉ូតូរបស់គេទៅ ពេលនោះឈ្មោះ [redacted] សេងហុង បានជិះម៉ូតូចេញទៅមុន ដោយខ្លួនឃើញម៉ូតូម៉ាកហុងដាឌ្រីម ស៊េរីឆ្នាំ២០១៩ ពណ៌ខ្មៅ ស្លាកលេខមិនចាំ ដែលនៅក្បែរគ្នានោះមានសោរម៉ូតូជាប់នឹងកែបស្រាប់ ទើបខ្លួនឱ្យឈ្មោះ [redacted] សេងហុង ជិះទៅមុនខ្លួន ទើបខ្លួនជិះម៉ូតូនោះទៅតាមក្រោយ។ ពេលខ្លួនជិះម៉ូតូទាន់ឈ្មោះ [redacted] សេងហុង ពួកខ្លួនបាននិយាយគ្នាលេងហើយឈ្មោះ [redacted] សេងហុង បានសួរខ្លួនថាបានម៉ូតូមកពីណា ខ្លួនប្រាប់ថាជាម៉ូតូរបស់បងប្រុសរបស់ខ្លួនខ្ចីគាត់ជិះសិន បន្ទាប់មកខ្លួនក៏ជិះម៉ូតូវាឈ្មោះ [redacted] សេងហុង គោលបំណងទៅផ្សារព្រំ ខេត្តប៉ៃលិន។ ពេលខ្លួនជិះមកតាមផ្លូវទៅស្រុកម៉ាឡៃ ហួសផ្លូវកូនដំរីបានបន្តិច ស្រាប់តែឈ្មោះ [redacted] សេងហុង បានទូរសព្ទមកខ្លួនដើម្បីខ្ចីលុយចាក់សាំងម៉ូតូសិន។ បន្ទាប់ពីចាក់សាំង

ហើយខ្លួនក៏បបួលឈ្មោះ [redacted] សេងហុង ទៅលេងស្រុកម៉ាឡៃ ពេលទៅដល់ខ្លួនក៏ទៅកន្លែងបញ្ចាំម៉ូតូឈ្មោះ បារាំង ប៉ុន្តែគាត់មិនហ៊ានទទួលបញ្ចាំ ដោយសារម៉ូតូនោះគ្មានឯកសារ។ បន្ទាប់មកខ្លួនក៏ជិះម៉ូតូទៅកន្លែងព្រៃ និងខ្ចីតួណាវីស និងខ្ចីកូនសោរពីឈ្មោះបារាំង ដោយកុហកគាត់ថា ខ្ចីយកទៅដោះម៉ូតូដែលរលត់។ បន្ទាប់ពីដោះអាវ និង GPS ចេញរួច ខ្លួនបានយកអាវម៉ូតូនិង GPS ទៅផ្ញើ និងផ្ទះរបស់ឈ្មោះ បារាំង ដោយប្រាប់គាត់ថាខ្លួនយកម៉ូតូទៅលាងសិន។ ពេលនោះខ្លួនបានលឺឈ្មោះ បារាំង បាននិយាយទូរសព្ទជាមួយមនុស្សម្នាក់អាចជាម្ចាស់ម៉ូតូគេកំពុងរកខ្លួន និងម៉ូតូរបស់គេវិញ ភ្លាមនោះខ្លួនក៏យកម៉ូតូនោះទៅទុកនៅក្បែរសាលារៀនសិន រួចដើរមករកឈ្មោះ [redacted] សេងហុង ដោយពេលនោះខ្លួនបានបបួលឈ្មោះ [redacted] សេងហុង ទៅដកលុយកន្លែងវីង ខណៈនោះមានរថយន្តក្រុងសារធារណៈបើកកាត់នោះខ្លួន និងឈ្មោះ [redacted] សេងហុង ជិះឡានមកដកលុយនៅកូនដំរី បន្ទាប់ពីដកលុយបានហើយ ខ្លួនបានម៉ៅឡានទៅខេត្តសៀមរាប ដោយម៉ូតូរបស់ឈ្មោះ [redacted] សេងហុង នៅកន្លែងលាងម៉ូតូនៅស្រុកម៉ាឡៃ ខ្លួនបានឱ្យឡានទៅយកម៉ូតូឈ្មោះ [redacted] សេងហុង ពេលខ្លួនទៅដល់កន្លែងលាងម៉ូតូក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ នៅក្នុងរឿងនេះខ្លួនបានដឹងកំហុសហើយ ខ្លួនសំណូមពរសុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

៣.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សេងហុង** បានឆ្លើយនាពេលសវនាការថា : កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ៤:១០ព្រឹក ខ្លួនបានជិះម៉ូតូពីខេត្តសៀមរាប មកក្រុងប៉ោយប៉ែត ក្នុងគោលបំណងទៅទិញប៉ុងឡានក្រុងឱ្យឪពុកខ្លួន។ ស្រាប់តែឈ្មោះ [redacted] ទី បានទាក់ទងខ្លួន ដោយបបួលខ្លួនលេងហ្គេម ប៉ុន្តែខ្លួនមិនលេងទេ ដោយជាប់រវល់រកទិញប៉ុងឡានក្រុងឱ្យឪពុក។ ពេលនោះខ្លួនបានឱ្យឈ្មោះ [redacted] ទី ជួយជូនដើររកកន្លែងលក់ប៉ុងឡាន ប៉ុន្តែរកមិនបាន ខ្លួនបានដេកនៅក្រុងប៉ោយប៉ែត ចំនួន០១យប់។ លុះព្រឹកឡើងនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២០ ខ្លួនក៏ដើរទៅរកម៉ូតូរបស់ខ្លួនចំណែកឈ្មោះ [redacted] ទី បានដើរទៅរកម៉ូតូម៉ាកហុងដាឌ្រីមមួយគ្រឿងទៀត ខ្លួនមិនដឹងថាមានកូនសោរឬអត់ទេ។ បន្ទាប់មកខ្លួនក៏ជិះម៉ូតូចេញទៅមុន ចំណែកឈ្មោះ [redacted] ទី ក៏បានជិះម៉ូតូតាមពីក្រោយបានប្រហែល១០ម៉ែត្រ ខ្លួនក៏សួរឈ្មោះ [redacted] ទី ថាបានម៉ូតូមកពីណា ឈ្មោះ [redacted] ទី ឆ្លើយថាជាម៉ូតូបងប្រុសរបស់គាត់(លីទី)ពេលខ្លួនជិះមកដល់កូនដំរីម៉ូតូរបស់ខ្លួនក៏អស់សាំង ហើយខ្លួនក៏ខ្ចីលុយរបស់ឈ្មោះ [redacted] ទី ចំនួន ២០.០០០(ពីរម៉ឺន)រៀល ពេលនោះឈ្មោះ [redacted] ទី បានជិះម៉ូតូទៅផ្ទះបងប្រុសរបស់គេ ហើយឈ្មោះ [redacted] ទី បានប្រាប់ខ្លួនថាគេទៅ ខេត្តសៀមរាបដែរ។ ខ្លួនចូលលាងម៉ូតូប្រហែល១៥នាទី បន្ទាប់មកឈ្មោះ [redacted] ទី ក៏ដើរត្រឡប់មកវិញ ប៉ុន្តែមិនឃើញម៉ូតូនោះទេ ហើយឈ្មោះ [redacted] ទី បានបបួលខ្លួនទៅបើកប្រាក់នៅកូនដំរី ហើយខ្លួនក៏បានទុកម៉ូតូរបស់ខ្លួននៅកន្លែងលាងម៉ូតូទាំងកូនសោររួចខ្លួនក៏ជិះឡានក្រុងជាមួយឈ្មោះ [redacted] ទី មកកូនដំរី ដើម្បីបើកប្រាក់។ បន្ទាប់មកខ្លួន និងឈ្មោះ [redacted] ទី ក៏ជិះឡានតាក់ស៊ីមកយកម៉ូតូរបស់ខ្លួនវិញ ក៏ត្រូវសមត្ថកិច្ចបានឃាត់ខ្លួនតែម្តង។ នៅក្នុងរឿងនេះខ្លួនបានដឹងកំហុសហើយ ខ្លួនសំណូមពរសុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

៤.តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុខៀត** បានឆ្លើយនាពេលសវនាការថា : កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២០ វេលាម៉ោងប្រហែល០៩:៣០នាទីព្រឹក ខ្លួនបានជិះម៉ូតូទៅធ្វើការងារនៅមុខផ្ទះសំណាក់ [redacted] ហ្វូវ ខ្លួនបានចតម៉ូតូនៅមុខផ្ទះសំណាក់រយៈពេល០២ម៉ោងជាង លុះពេលខ្លួនចេញមកវិញស្រាប់តែបាត់ម៉ូតូតែម្តង។ ពេលនោះម៉ូតូរបស់ខ្លួនមានភ្ជាប់ប្រព័ន្ធ GPS ហើយដឹងថាម៉ូតូជិះទៅស្រុកម៉ាឡៃ ដោយដឹងថានៅស្រុកម៉ាឡៃ មានអ្នកទទួលទិញម៉ូតូចោរ។ ក្រោយមកខ្លួនក៏ប្តឹងសមត្ថកិច្ច ហើយសមត្ថកិច្ចក៏បានធ្វើការឃាត់ខ្លួនឈ្មោះ [redacted] សេងហុង ភេទប្រុស និងឈ្មោះ [redacted] ទី ភេទប្រុស តែម្តង។ ខ្លួនសូមឆ្លើយ

បញ្ជាក់ថាម៉ូតូរបស់ខ្លួនម៉ាក ហុងដាឌ្រីម ស៊េរីឆ្នាំ២០១៩ ពណ៌ខ្មៅពាក់ស្លាកលេខ បន្ទាយមានជ័យ1U-3137 ត្រូវបានចោរដោះខ្ទចខ្ទីអស់។ នៅក្នុងរឿងនេះខ្លួនខ្លួនមិនទាមទារសំណងជម្ងឺចិត្តពីជនជាប់ចោទឡើយ។

៥.តាមរយៈចម្លើយរបស់ជនជាប់ចោទ មានលក្ខណៈច្បាស់លាស់ស៊ីសង្វាក់ទៅនឹងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងផ្សេងៗដែលមាននៅក្នុងសំណុំរឿង អាចធ្វើឱ្យតុលាការជឿជាក់បានថា ពិតជាមានករណីនៃអង្គហេតុ "**លួច**" ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] **ទី** និងឈ្មោះ [redacted] **សេងហុង** ប្រាកដមែន។

៦.ផ្អែកតាមសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **ទី** និងឈ្មោះ [redacted] **សេងហុង** បានបង្ហាញពីចេតនាទុច្ចរិត ក្នុងការលួចម៉ូតូរបស់អ្នកដទៃ ដែលនេះជាអំពើ "**លួច**" ដោយច្បាប់តម្រូវឱ្យធ្វើការផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៧.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា : តាមចម្លើយរបស់ជនជាប់ចោទ និងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងភស្តុតាងផ្សេងៗដែលមាននៅក្នុងសំណុំរឿង សរបញ្ជាក់ឱ្យឃើញថា ពិតជាមានករណី "**លួច**" ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] **ទី** និងឈ្មោះ [redacted] **សេងហុង** ប្រាកដមែន។ ដូចនេះប្តឹងសុំឱ្យលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនទាំងនេះទៅតាមច្បាប់ ជាការសន្និដ្ឋានគប្បីពិចារណា។

៨.មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **ទី** ភេទប្រុស កើតថ្ងៃទី២៥.០១.២០០៣ និងឈ្មោះ [redacted] **សេងហុង** ភេទប្រុស កើតថ្ងៃទី២២.១០.២០០២ ពីបទ "**លួច**" ប្រព្រឹត្តនៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៩.ជនជាប់ចោទឈ្មោះ [redacted] **ទី** និងឈ្មោះ [redacted] **សេងហុង** សុទ្ធតែជាអនីតិជន មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវលើអំពើប្រព្រឹត្តរបស់ខ្លួន ហើយអំពើនេះបានធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម និងទ្រព្យសម្បត្តិរបស់អ្នកដទៃ ដែលច្បាប់បញ្ញត្តិឱ្យទទួលខុសត្រូវព្រហ្មទណ្ឌជាធរមាន។

១០.ទោះបីជាជនជាប់ចោទឈ្មោះ [redacted] **ទី** និងឈ្មោះ [redacted] **សេងហុង** បានប្រព្រឹត្តកើតឡើងក៏ពិតប្រាកដមែន ដែលតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងក្រមព្រហ្មទណ្ឌ និងសន្ធិសញ្ញាស្តីពីការការពារកុមារគឺបានផ្តល់ ផលប្រយោជន៍ទៅឱ្យអនីតិជន លើសពីនេះទៀតក៏បានផ្តល់នូវស្ថានសម្រាលទោស ដែលជាប្រយោជន៍ទៅឱ្យអនីតិជនដោយការកាត់បន្ថយនូវពាក់កណ្តាលនៃអតិបរមា និងត្រូវបន្ថយពាក់កណ្តាលនៃអប្បបរមាលើសពី១ថ្ងៃ តាមក្រមព្រហ្មទណ្ឌ។

១១.វត្ថុតាងដែលដកហូតមាន ទូរសព្ទចំនួន ០១គ្រឿង ម៉ាក HUAWEI ពណ៌ស សភាពបែកកញ្ចក់ IMEL1 863980031295834/IMEL2 863980031335846 ដកហូតពីឈ្មោះ **ប៊ុន សេងហុង** រក្សាទុកនៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តបន្ទាយមានជ័យ **គប្បីប្រគល់ឱ្យម្ចាស់ដើមវិញ**។

១២.ដើមបណ្តឹងរដ្ឋប្បវេណីមិនបានទាមទារសំណងឡើយ គប្បីតុលាការមិនពិចារណាពីបញ្ហានេះទេ។

## <u>ហេតុដូចនេះសម្រេច</u>

I. **ផ្តន្ទាទោសជនជាប់ចោទ ៖**

១.ឈ្មោះ [redacted] **ទី** ភេទប្រុស កើតថ្ងៃទី២៥.០១.២០០៣ អនីតិជន សញ្ជាតិខ្មែរ មុខរបរគ្មាន សាសនាព្រះពុទ្ធទីកន្លែងកំណើតភូមិ[redacted]ខេត្តក្រចេះ អាសយដ្ឋានមុនពេលឃុំខ្លួនភូមិ[redacted]



Scanned with CamScanner

[redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ[redacted]ង៉ីវ (រស់) ម្ដាយឈ្មោះ [redacted] ម៉ៃ (រស់) នៅលីវ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ ធ្លាប់ចូលមណ្ឌលអប់រំកែប្រែភ្នំបាក់ឆ្នាំ២០២០។ (ក្នុងឃុំ)

(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ : ៦៣៨ ព្រ.ទ III "គ"/២០ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០)

២.ឈ្មោះ [redacted] **សេងហុង** ភេទប្រុស កើតថ្ងៃទី២២.១០.២០០២ អនីតិជន សញ្ជាតិខ្មែរ មុខរបរជាងឡាន សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ[redacted] ខេត្តសៀមរាប អាសយដ្ឋានមុនពេលឃុំខ្លួនភូមិ[redacted] ខេត្តសៀមរាប ឪពុកឈ្មោះ[redacted]ហួយ (រស់) ម្ដាយឈ្មោះ[redacted] សុភាព (រស់) ប្រពន្ធឈ្មោះ [redacted]រក្សា មានកូនចំនួន ០២នាក់ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ ធ្លាប់ចូលមណ្ឌលអប់រំកែប្រែសៀមរាបចំនួន០២ខែ។ (ក្នុងឃុំ)

(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ : ៦៣៩ ព្រ.ទ III "គ"/២០ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០)

**ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០៦(ប្រាំមួយខែ)** ពីបទ **"លួច"** ប្រព្រឹត្តនៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

II. **វត្ថុតាងដែលដកហូតមាន** ទូរសព្ទចំនួន ០១គ្រឿង ម៉ាក HUAWEI ពណ៌ស សភាពបែកកញ្ចក់ IMEL1 863980031295834/IMEL2 863980031335846 ដកហូតពីឈ្មោះ ប៊ុន សេងហុង រក្សាទុកនៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តបន្ទាយមានជ័យ **ត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ**។

III. សាលក្រមនេះជំនុំជម្រះ និងប្រកាសជាអសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ទី** និងឈ្មោះ[redacted] **សេងហុង** និងចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted] **សុខៀត** ។

បើកសិទ្ធិឱ្យប្ដឹងឧទ្ធរណ៍តាមកំណត់របស់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៥កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១

**ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner